អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីពិចារណារបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/២។

ក្រោយពេលស៊ើបអង្កេតដែលមានរយៈពេល ១០ ឆ្នាំរួចមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាចោទប្រកាន់បញ្ជូន អោ អាន ទៅជំនុំជម្រះ ហើយនៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាលើកលែងចោទប្រកាន់រាល់បទចោទទាំងអស់មកលើរូបគាត់។ ជាលើកដំបូងនៅក្នុងប្រវត្តិតុលាការ អង្គបុរេជំនុំជម្រះត្រូវប្រឈមនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នា ចេញពីការិយាល័យតុលាការតែមួយ។

បន្ទាប់មក អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ពីសហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ និង ពីសហមេធាវីការពារក្តី អោ អាន នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ដែលជំទាស់ទៅនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង បណ្តឹងឧទ្ធរណ៍ពីសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ដែលជំទាស់ទៅនឹងដីកាលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ។

នៅថ្ងៃទី១៩ ទី២០ និង ទី២១ ខែមិថុនា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានដំណើរការសវនាការក្នុងសំណុំរឿង ០០៤/២ ដើម្បីស្តាប់ទឡ្ហីករណ៍នានារបស់ភាគី។

## *ផ្នែកនៃសេចក្តីសម្រេចរួម ដែលអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ*

ជាបឋម ក្រោយពេលបានពិនិត្យទៅលើសំណុំរឿងយ៉ាងយកចិត្តទុកដាក់រួចមក អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ក្នុងពេលដំណាលគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ដោយរំលោភទៅលើមូលដ្ឋានគ្រឹះនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

អង្គបុរេជំនុំជម្រះយល់ឃើញថា ការបើកកិច្ចស៊ើបសួររួមគ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ គឺជាគោលការណ៍គតិយុត្តិចម្បងជាមូលដ្ឋាននៅ អ.វ.ត.ក (នៅត្រង់កថាខណ្ឌ ១០៣)។ ពិសេសជាងនេះទៀត នៅ

ក្នុងករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធនឹងបញ្ហានានាដែលត្រូវសម្រេចដោយដីកាដំណោះស្រាយ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ឃើញថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក អនុញ្ញាតឲ្យមានដំណើរការសកម្មភាពតែពីរប៉ុណ្ណោះ អនុលោមតាមមាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក និង វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការព្រមព្រៀងដោយតុល្យភាព ឬដោយផ្ទាល់ទៅលើបញ្ហាទាំងនោះ ឬបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនទៅលើបញ្ហាទាំងនេះទៅអង្គបុរេជំនុំជម្រះ (នៅត្រង់កថាខណ្ឌ ១២០)។

អង្គបុរេជំនុំជម្រះបានបញ្ជាក់បំភ្លឺបន្ថែមលើសិទ្ធិអំណាចរបស់ខ្លួនទៅលើដំណាក់កាលស៊ើបអង្កេត (នៅត្រង់កថាខណ្ឌ ៣១-៥៤)។ អង្គជំនុំជម្រះបានបញ្ជាក់ថា អ.វ.ត.ក គឺជាតុលាការពិសេសនៅក្នុងប្រព័ន្ធតុលាការកម្ពុជា (នៅត្រង់កថាខណ្ឌ ៥៨) និងបានអះអាងជាថ្មីពីការយល់ឃើញជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/១ ថា ច្បាប់ជាធរមាននៅ អ.វ.ត.ក មិនរារាំងដល់យុត្តាធិការជាតិទេ ហើយថា តុលាការកម្ពុជាធម្មតាមានយុត្តាធិការពេញលេញទៅលើបញ្ហានានានៃយុត្តិធម៌ព្រហ្មទណ្ឌ (នៅត្រង់កថាខណ្ឌ ៥៩)។

អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតរយៈពេល ១៦ ខែ ក្រោយពីការជូនដំណឹងជាលើកទីពីរនូវការបញ្ចប់កិច្ចស៊ើបសួរ ហើយយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានចេញដីកាដំណោះស្រាយក្នុងអំឡុងចិរវេលាសមរម្យទេ (នៅត្រង់កថាខណ្ឌ ៦២ និង ៧០)។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

### *មតិយោបល់របស់ចៅក្រមជាតិ*

ចៅក្រមជាតិយល់ឃើញថា ប្រវត្តិនៃការចរចាដែលនាំឲ្យបង្កើតកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា បង្កើតឲ្យមានការចោទប្រកាន់តែបុគ្គលចំនួនតិចតួចប៉ុណ្ណោះនៅ អ.វ.ត.ក (នៅត្រង់កថាខណ្ឌ ២០៣) ទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ចៅក្រមជាតិបានសន្និដ្ឋានថា បុគ្គលប្រាំពីររូប ដែលជាសមាសភាពនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក ត្រូវបានចាត់ទុកជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ (នៅត្រង់កថាខណ្ឌ ២២៣) ចំណែក កាំង ហ្កេកអ៊ាវ មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទេ។

ទាក់ទិននឹងសំណុំរឿង ០០៤/២ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតជាតិបានធ្វើការស៊ើបអង្កេតយ៉ាងល្អិតល្អន់ (នៅត្រង់កថាខណ្ឌ ២៨១) ហើយហេតុនេះយល់ឃើញថា ដីកាលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ ធ្វើឡើងត្រឹមត្រូវតាមផ្លូវច្បាប់ និងគួរតែត្រូវបានតម្កល់។

ម្យ៉ាងវិញទៀត ចៅក្រមជាតិយល់ឃើញថា សកម្មភាពដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើឡើង គឺផ្ទុយទៅនឹងគំនិតរបស់អ្នកតាក់តែងច្បាប់ រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ យុត្តិសាស្ត្រអន្តរជាតិ និង ការអះអាងពីមុនៗរបស់ខ្លួនផង (នៅត្រង់កថាខណ្ឌ ២៩៣)។ ចៅក្រមជាតិយល់ឃើញផងដែរថាការចេញដីកាសម្រេចពីរផ្ទុយគ្នាបែបនេះ បង្កើតបានជាចន្លោះប្រហោងនៃច្បាប់ (កថាខណ្ឌ២៩៥)។ ហើយក្នុងករណីដែលច្បាប់ពុំមានចែងដូច្នេះ ហើយដើម្បីដោះស្រាយបញ្ហាជាប់គាំងក្នុងសំណុំរឿង ០០៤/២ នេះបាន ចៅក្រមជាតិយល់ថាការបកស្រាយច្បាប់ ឬវិធាននានា រួមទាំងវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងផងដែរនោះ គប្បីធ្វើឡើងដោយពិចារណាទៅលើផលប្រយោជន៍ជនត្រូវចោទ (កថាខណ្ឌ២៩៦, ៣០១)។ ហេតុនេះ ចៅក្រមជាតិបានសន្និដ្ឋានថា ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវចាត់ទុកជាមោឃៈ ហើយដីកាដំណោះស្រាយ (លើកលែងចោទ) ត្រូវតម្កល់ទុកជាបានការ ។

### *មតិយោបល់របស់ចៅក្រមអន្តរជាតិ*

តាំងពីដំបូងមក ចៅក្រមអន្តរជាតិបានសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតប្រើប្រាស់សិទ្ធិអំណាចដោយមិនត្រឹមត្រូវ ដែលចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា និងផ្ទុយគ្នា (នៅត្រង់កថាខណ្ឌ ៣១៣)។ ចៅក្រមអន្តរជាតិបានដោះស្រាយពីសុពលភាពរបស់ដីកាដំណោះស្រាយទាំងពីរ (នៅត្រង់កថាខណ្ឌ ៣១៧-៣២៦) ដោយសារដីកាទាំងពីរនេះមានភាពខុសគ្នា មិនអនុលោមទៅតាមច្បាប់ជាធរមាននៅ អ.វ.ត.ក។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ជាការសមហេតុផលដែលត្រូវយោងទៅពាក្យពេចន៍នៃមាត្រា ៥(៤), ៦(៤) និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២០*ថ្មី* និង ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក និង វិធាន ១៣(៥), ១៤(៧), ៧១ និង ៧២ នៃវិធានផ្ទៃក្នុងដែលថា កម្មវត្ថុគន្លឹះនៃយន្តការដោះស្រាយករណីខ្វែងយោបល់គឺដើម្បីបញ្ចៀសការរាំងស្ទះដែលបង្អាក់កិច្ចដំណើរការនីតិវិធីមិនឲ្យបន្តដំណើរការទៅការជំនុំជម្រះ (នៅត្រង់កថាខណ្ឌ ៣២៣)។

ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺ *ហួសដែនអំណាច* ហើយហេតុនេះ ត្រូវទុកជាមោឃៈ ចំណែកដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតមានសុពលភាព (នៅត្រង់កថាខណ្ឌ ៣២៦) ហើយអាស្រ័យហេតុនេះ អោ អាន ត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ក្រោយពីពិនិត្យទៅលើមូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍ដែលទទួលយកបានរួចមក ចៅក្រមអន្តរជាតិ បានកែប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចំពោះបទប្រល័យពូជសាសន៍ (នៅត្រង់កថាខណ្ឌ ៦៣២)។ លើសពីនេះទៀត អនុលោមតាមវិធាន ៤៤ នៃវិធានផ្ទៃក្នុង និងអង្គហេតុនានាដែលមានក្នុងកំណត់ហេតុ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយមិនបានពិចារណាទៅលើវិធានការសន្តិសុខនានាដែលខ្លួនអាចយកមកប្រើប្រាស់បាន។ ដោយ

ហេតុថា អោ អាន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត ដូចជា បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង បទនុស្សឃាត ចៅក្រមអន្តរជាតិគួរតែចេញដីកាបង្គាប់ឲ្យចាប់ខ្លួនគាត់ (កថាខណ្ឌ ៦៨៨-៦៩៣) ។

ដោយសារមិនទទួលបានការគាំទ្រដោយសំឡេងភាគច្រើនលើសលុបលើសពី៤រូប ស្ថានភាពនេះស្ថិតក្រោមបញ្ញត្តិនៃវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។ ដីកាដំណោះស្រាយ (សម្រេចបញ្ជូនទៅជំនុំជម្រះ)មិនអាចត្រូវបានបដិសេធទេ ហេតុនេះត្រូវមានសុពលភាព។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អាចរកមើលបាននៅលើគេហទំព័រ៖

https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D359_24_KH_0.PDF

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***


លោក **នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈនិងជាអ្នកនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥១២ ៤៨៨ ១៥៦(០)
អ៊ីមែល៖ neth.phektra@eccc.gov.kh